## ៣-២ នមស្សការ ថ្វាយបង្គំ ព្រះធម៌

-**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ,

-**ធម្មោ** ព្រះនព្វលោកុត្តរធម៌ មាន ៩ប្រការគឺ មគ្គ៤ ផល៤ និព្វាន១,

-**សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺជានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង,

-**អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល (គឺបដិបត្តិបានគ្រប់ពេល) គឺថាបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ,

-**ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន (ឬ ពិសោធបាន),

-**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា,

-**បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន,

-**តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់ដ៏ប្រកបព្រមហើយដោយគុណមានគុណថា ស្វាក្ខាតោ ជាដើមនោះ ដោយសិរសា គឺត្បូង,

-**តញ្ហ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ ជាម្ចាស់ ដោយគ្រឿងសក្ការៈ ទាំងឡាយ មានប្រមាណ ប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេងៗ